## វេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៤៤

# របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

*ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២១*
*ម៉ោង ៨ :៣០ព្រឹក ដល់ ១៥:៣០ រសៀល*
***នៅមជ្ឈមណ្ឌលដាយកូនៀ** និង តាមរយៈប្រព័ន្ធអនឡាញ **Zoom Meeting***

## I. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យមួយស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ ក្នុងនោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏ស្ថិតក្រោមច្បាប់ការងារនេះដែរ ហើយសមត្ថភាពរបស់អង្គការសមាគមនៅមានកម្រិតក្នុងការស្វែងយល់ពីអនុក្រឹត្យនេះ ដែរតម្រូវឲ្យមានការពន្យល់បន្ថែម។

ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានលើកឡើងតាមរយៈក្រុមការងារគ្រប់គ្រងធនធានមនុស្ស ក៏ស្នើឲ្យលើកប្រធានបទ **របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ** គឺជាប្រធានបទសំខាន់និងមានភាពចាំបាច់ណាស់សម្រាប់អង្គការ និងសមាគមមិនមែនរដ្ឋាភិបាល ។

ដើម្បីឆ្លើយតបនឹងតម្រូវការសមាជិករបស់ខ្លួនផង និងចូលរួមចំណែកទប់ស្កាត់នៃការរីករាលដាលនៃជម្ងឺកូវីដ ១៩ តាមរយៈការអនុវត្តវិធានការណ៍ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា **អង្គការ គ.ស.ក** នឹងរៀបចំវេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី៤៤ តាមរយៈការជួបផ្ទាល់ចំនួន ៥០នាក់ និង តាមរយៈប្រព័ន្ធអនឡាញ(Zoom Meeting) ក្រោមប្រធានបទ **របបប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។**

ត្រឹមខែតុលា ឆ្នាំ២០២១ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) មានសមាជិកសរុបទាំងអស់ប្រហែលចំនួន ២០០ ស្ថាប័ន ទាំងអង្គការក្នុងស្រុក និងអង្គការបរទេស ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុតសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

## II. គោលបំណងនៃវេទិការៀនសូត្រ

១. ចូលរួមផ្សព្វផ្សាយពីអនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

២. បង្កើនការយល់ដឹង និងអនុលោមភាពតាមអនុក្រឹត្យ

៣. បង្កើនទំនាក់ទំនងតាមប្រព័ន្ធអនឡាញ និងបណ្តាញទំនាក់ទំនងសង្គមក្នុងចំណោមអ្នកគ្រប់គ្រងធនធានមនុស្ស

## III. អ្នកចូលរួមគោលដៅ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ **អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស** ដែលអញ្ជើញមកពី **សមាគម និងអង្គការមិនមែនរដ្ឋាភិបាល** ក្នុងប្រទេសកម្ពុជា។

## IV. អ្នកចូលរួម និងសេវាកម្ម

សម្រាប់ សមាគម និងអង្គារមិនមែនរដ្ឋាភិបាលជាសមាជិក និងបណ្តាញអង្គការមិនមែនរដ្ឋាភិបាលតាមខេត្តៈ

- ផ្តល់ជូន០២ (ពីរ)នាក់ ក្នុងមួយស្ថាប័នដោយតតបង់ថ្លៃ ។ ការបង់ថ្លៃចូលរួមគឺតម្រូវឲ្យមានប្រសិនបើស្ថាប័នបញ្ជូនបុគ្គលិករបស់ខ្លួនចូលរួមលើសពី ០២(ពីរ) នាក់។ ថ្លៃចូលរួមគឺត្រូវអនុវត្តចាប់ពីនាក់ទី៣ឡើងទៅ ១០ ដុល្លារ/មួយនាក់/វគ្គ។

សម្រាប់អង្គការ មិនមែនជាសមាជិករបស់អង្គការ គ.ស.ក គឺតម្រូវឲ្យបង់ថ្លៃចូលរួមៈ

- តម្លៃ ២០ដុល្លារ ក្នុង ០១ (មួយ) នាក់ ក្នុងមួយវគ្គ។

**ចំណាំៈ** អ្នកចូលរួម តម្រូវឲ្យបង់ថ្លៃចូលរួម យ៉ាងហោចណាស់២ថ្ងៃ មុនកាលបរិច្ឆេទវេទិកា។

## V. របៀបចុះឈ្មោះ

អ្នកចូលរួមទាំងអស់តម្រូវឲ្យចុះឈ្មោះជាមុន ដើម្បីទទួលបានតំណរថ្មី (New Link) ពីក្រុមការងារ អង្គការ គសក ក្នុងការចូលរួមវេទិការៀនសូត្រនេះ។ តំណរនឹងផ្ញើជូនអ្នកដែលបានចុះឈ្មោះ និងបំពេញតាមលក្ខខណ្ឌ**មួយថ្ងៃមុនវេទិកា**រៀនសូត្រចាប់ផ្តើម។

សម្រាប់អ្នកចូលរួមដោយផ្ទាល់ ក្រុមការងារនឹងផ្ញើបញ្ជីឈ្មោះត្រឡប់វិញ ដើម្បីបញ្ជាក់ពីការចូលរួមដោយផ្ទាល់របស់ លោក លោកស្រី។

VI. **របៀបវារៈ**

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០-០៨:៣០ | ការចុះឈ្មោះអ្នកចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ | ក្រុមការងារ គ.ស.ក |
| ០៨:៣០-០៨:៤៥ | - ការណែនាំពីរបៀបប្រើ Zoom Meeting និង បទបញ្ជាផ្ទៃក្នុងវគ្គ<br>- គោលបំណងវេទិការៀនសូត្រ | **លោក លឹម ឌីណា**<br>អ្នកឯកទេសផ្នែកកៀរគធនធាន អង្គការ គ.ស.ក |
| ០៨:៤៥-០៩:០០ | កិច្ចស្វាគមន៍ និងបើកកម្មវិធី | **អ្នកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិ អង្គការ គ.ស.ក |
| ០៩:០០-១០:៣០ | **បទបង្ហាញពី៖ អនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**<br>- លក្ខខណ្ឌ និងតាវលិក សោធនជរាភាព<br>- លក្ខខណ្ឌ និងតាវលិក វិភាជន៍ជរាភាព<br>- លក្ខខណ្ឌ និងតាវលិក សោធនទុព្វភាព<br>- សោធនឧត្តរជីវី | **មន្រ្តីជំនាញពីក្រសួងការងារ** |
| ១០:៣០-១០:៤៥ | សម្រាកអាហារសម្រ៉ន់ | ក្រុមការងារ គ.ស.ក |
| ១០:៤៥-១២:០០ | **វេទិការសំណួរចម្លើយ (វគ្គទី១)** | **មន្រ្តីជំនាញពីក្រសួងការងារ** |
| ១២:០០-១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ | ក្រុមការងារ គ.ស.ក |
| ១៣:៣០-១៤:៣០ | **បទបង្ហាញពី៖ អនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**<br>- លក្ខខណ្ឌ និងសិទ្ធិនៃការចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត<br>- សោធនជរាភាពតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ<br>- លក្ខខណ្ឌទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ | **មន្រ្តីជំនាញពីក្រសួងការងារ** |
| ១៤:៣០-១៥:១៥ | **វេទិការសំណួរចម្លើយ (វគ្គទី២)** | **មន្រ្តីជំនាញពីក្រសួងការងារ** |
| ១៥:១៥-១៥:៣០ | បិទកម្មវិធី | តំណាងសមាជិកក្រុមការងារ (HR Working Group) |
| ១៥:៣០ | សម្រាកអាហារសម្រ៉ន់ | ក្រុមការងារ គ.ស.ក |

***កំណត់សម្គាល់:*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែ របៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។*